# របាយការណ៍

# វេទិកាជាតិលើកទី០១ ស្តីពីការងារជនមានពិការភាព



˂˂បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្តល់សេវាការងារដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា˃˃

រៀបចំដោយ៖

ភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩៨

# មាតិការ


**ពាក្យកាត់ ........................................................................................................................4**

**១. សេចក្តីផ្តើម ......................................................................................................................... 5**

១.១. មតិស្វាគមន៍របស់តំណាងអង្គការសាលារៀនទន្សាយ និងតំណាងអង្គការ អុកហ្វាមកម្ពុជា )OXFAM CAMBODIA) ........................................................................................................................5

១.២. សន្ទរកថាតំណាងនាយកដ្ឋានសុខមាលភាពជនពិការ ...........................................................6

១.៣. សន្ទរកថាបើកវេទិកាបើក របស់ឯកឧត្តម **ឯកឧត្តម ញឹក ចន្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ) អតីតយុទ្ធជន និងយុវនីតិសម្បទា) ........................................................................................6

**២. បទបង្ហាញ ការអនុវត្តល្អ និងសមិទ្ធផលនានា ស្តីពី ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់សេវាការងារ ការស្រាវជ្រាវអំពីវិស័យការងារ និង ជួយគាំទ្រសេវាដល់យុវជនមានពិការភាពនៅកម្ពុជា....................................................7**

២.១. បទបង្ហាញរបស់ បទបង្ហាញរបស់លោកយៀប ម៉ាលីណូ ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ ស្តីពី បញ្ហាប្រឈមរបស់ជនមានពិការភាព សិទ្ធិស្មើគ្នារបស់ជនពិការ ច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងទិន្នន័យជនពិការចូលបម្រើការងារក្នុងស្ថាប័នរដ្ឋ និងឯកជន។ .........................................7

២.២. បទបង្ហាញរបស់ តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់ ស្តីពី "បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្តល់សេវាការងារ ដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា" ...............................7

**៣. បញ្ចាំងវិដេអូនិងចែករំលែកបទពិសោធន៍អំពីភាពជោគជ័យរបស់យុវជនមានពិការភាព .....................8**

**៤. ពិភាក្សាក្រុមតូចស្តីពី( "បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្តល់សេវាការងារ ដល់យុវជនមានពិការភាព) .............8**

**៥. វេទិកាពិភាក្សា (សំណួរ ចម្លើយ ក្រុមធំ) ដោយមានការចូលរួមពីវាគ្មិន ........................................8**

**៦. សន្ទរកថាសង្ខេប និង សកម្មភាពបន្ទាប់ របស់តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់...............10**

**៧. សុន្ទរកថាបិទកម្មវិធី (ដោយលោក យៀប ម៉ាលីណូ) ប្រធាននាយកដ្ឋានអប់រំសុមាលភាពជនពិការ) .................12**

**ឧបសម្ព័ន្ធទី០១៖** លទ្ធផលពិភាក្សាតាមក្រុមតូចលើបញ្ហាប្រឈម និង ដំណោះស្រាយក្នុងការទទួលការងាររបស់យុវជនមានពិការភាព...................................................................................................................13

ក្រុមទី១៖ ក្រុមអាណាព្យាបាល (Parents) ..........................................................................13

ក្រុមទី២៖ ក្រុមវិស័យឯកជនដែលផ្តល់ការងារ(Employer)........................................................14

ក្រុមទី៣៖ ក្រុមទីភ្នាក់ងារផ្តល់ការងារ (Job Agency) ..............................................................15

ក្រុមទី៤៖ ស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិ )National Level) ...........................................................15

ក្រុមទី៥៖ ក្រុមអជ្ញាធរថ្នាក់ក្រោមជាតិ )Sub-national level)......................................................16

ក្រុមទី៦៖ ក្រុមអង្គការមិនមែនរដ្ឋាភិបាល )NGOs) .................................................................17

**ឧបសម្ព័ន្ធទី០២៖** សន្ទរកថាបើករបស់ ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន យុវនិតិសម្បទា ........................................................................................................................ 18

**ឧបសម្ព័ន្ធទី០៣៖** សន្ទរកថារបស់លោកហ៊ុនទូច ប្រធានអង្គការសាលារៀនទន្សាយ ........................................ 22

**ឧបសម្ព័ន្ធទី០៤៖** សន្ទរកថារបស់ លោក យៀម ម៉ាលីណូ ប្រធាននាយកដ្ឋានសុខមាលភាពជនពិការ ............... 26

**ឧបសម្ព័ន្ធទី០៥៖** បទបង្ហាញរបស់ លោក យៀម ម៉ាលីណូ ប្រធាននាយកដ្ឋានសុខមាលភាពជនពិការ ............. 27

**ឧបសម្ព័ន្ធទី០៦៖** បទបង្ហាញរបស់ តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់ ស្តីពី "បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្តល់សេវាការងារ ដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា" .................. 30

**ឧបសម្ព័ន្ធទី០៧៖** បញ្ជីវត្តមានអ្នកចូលរួមវេទិការ ........................................................................ 33

**ឧបសម្ព័ន្ធទី០៨៖** របៀបវារៈសិក្ខាសាលានិងវេទិកាថ្នាក់ជាតិ ........................................................ 34

RSO

# ពាក្យកាត់

| | | |
|---|---|---|
| **CSO** | Civil Society Organization | អង្គការសង្គមស៊ីវិល |
| **CSR** | Cooperate Social Responsibity | ទទួលខុសត្រូវសង្គម |
| **DAC** | Disability Action Council | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| **DOE** | District Office of Education | ការិយាល័យអប់រំស្រុក |
| **DPO** | Disabled People's Organization | អង្គការជនពិការ |
| **MoEYS** | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoH** | Ministry of Health | ក្រសួងសុខាភិបាល |
| **MoI** | Ministry of Interior | ក្រសួងមហាផ្ទៃ |
| **MoLVT** | Ministry of Labour and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **NEA** | National Employment Agency | ទីភ្នាក់ងារជាតិ និងមុខរបរ |
| **ILO** | International Labor Organization | អង្គការពលកម្មអន្តរជាត |
| **MoSVY** | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **NGO** | Non-governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| **POE** | Provincial Office of Education | មន្ទីរអប់រំ យុវជន និងកីឡា |
| **RSO** | Rabbit School Organization | សាលារៀនទន្សាយ |
| **EPC** | Essential Personnel Center | អង្គការបណ្ឌលសារវ័ន្ទ |
| **HI** | Human and Inclusion | អង្គការ អេច អាយ |
| **KPF** | Komar Pikar Foundation | អង្គការមូលនិធិកុមារកម្ពុជា |
| **CDPO** | Cambodian Disabled People's Organization | អង្គការជនពិការកម្ពុជា |
| **LfF** | Light for the World | អង្គការពន្លឺពិភពលោក |
| **YWD** | Students with Disabilities | សិស្សពិការ |
| **NEFT** | National Employment Forum Team | ក្រុមវេទិកាការងារថ្នាក់ជាតិ |

# ១. សេចក្ដីផ្ដើម

នៅថ្ងៃព្រហស្បតិ៍ ៤រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពុទ្ធស័ករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៩ នាយកដ្ឋានសុខុមាលភាពជនពិការបានធ្វើកិច្ចសហការជាមួយអង្គការសាលារៀនទន្សាយ រៀបចំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ ស្ដីពីបញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្ដល់សេវាការងារដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សិក្ខាកាមចូលរួមក្នុងវេទិកានេះមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី សរុបចំនួន ១០៣នាក់ មកពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ទីភ្នាក់ងារជាតិនិងមុខរបរ ក្រសួងអប់រំ យុវជន និងកីឡា ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីមកពីការិយាល័យ និងមន្ទីរសង្គមកិច្ច ស្រុក ខេត្ត និងរាជធានី និងថ្នាក់ដឹកនាំនិងមន្ត្រីមកពីនាយកដ្ឋានពាក់ព័ន្ធរបស់សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអ្នកជាប់ពាក់ព័ន្ធផ្សេងៗ ។

**វេទិការយៈពេលមួយថ្ងៃនេះប្រព្រឹត្តទៅដោយផ្ដោតលើរបៀបវារៈសំខាន់ៗចំនួន០៧គឺៈ**

(១) ពិធីបើកវេទិកា (២)បទបង្ហាញ ការអនុវត្តល្អ និងសមិទ្ធផលនានា ស្ដីពី ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការផ្ដល់សេវាការងារ ការស្រាវជ្រាវអំពីវិស័យការងារ និង ជួយគាំទ្រសេវាដល់យុវជនមានពិការភាពនៅកម្ពុជា (៣) បញ្ចាំងវិដេអូនិងចែករំលែកបទពិសោធន៍អំពីភាពជោគជ័យរបស់យុវជនមានពិការភាព (៤) ពិភាក្សាក្រុមតូចស្ដីពី(៉បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្ដល់សេវាការងារ ដល់យុវជនមានពិការភាព) (៥) វេទិកាពិភាក្សា (សំណួរ ចម្លើយ ក្រុមធំ) ដោយមានការចូលរួមពីវាគ្មិន) ៦(. សន្ទរកថាសង្ខេប និងសកម្មភាពបន្ទាប់ របស់តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់ (៧) សុន្ទរកថាបិទកម្មវិធី (ដោយលោក យៀប ម៉ាលីណ្ឌប្រធាននាយកដ្ឋាននាយកដ្ឋាន សុខមាលភាពជនពិការ។

## ១.១. មតិស្វាគមន៍របស់តំណាងអង្គការសាលារៀនទន្សាយ និងតំណាងអង្គការ អុកហ្វាមកម្ពុជា (OXFAM CAMBODIA)

ជាកិច្ចចាប់ផ្ដើមពិធីបើកវេទិកា **ចំណាប់អារម្មណ៍របស់លោក ហ៊ុន ទូច** នាយកប្រតិបត្តិអង្គការសាលារៀនទន្សាយ បានលើកឡើងពីវេទិកាពិភាក្សាសាធារណៈថ្ងៃនេះ គឺមានគោលបំណងរកឲ្យឃើញនូវឧបសគ្គ ឬបញ្ហាប្រឈមដែលអ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្តគោលនយោបាយរួមមាន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗ បានជួបប្រទះផលលំបាកមួយចំនួន រវាងអ្នកទទួល និងអ្នកផ្ដល់សេវាសម្រាប់ជនមានពិការភាព ដើម្បីធ្វើអោយប្រាកដថាជនមានពិការភាពទទួលបានការអភិវឌ្ឍដោយប្រសិទ្ធភាព និងធ្វើសមាហរណកម្មជនមានពិការទៅក្នុងសហគមន៍វិញ និងប្រកបដោយនិរន្តភាព។

**ចំណាប់អារម្មណ៍របស់លោកស្រី សុខ ចន្ទធរី** ប្រធានកម្មវិធី អុកហ្វាមកម្ពុជា បានលើកឡើងពីក្តីកង្វល់មួយចំនួនដែលលោកស្រីបានជួបប្រទះដូចជា ការយល់ដឹងនូវមានកម្រិត មានការរើសអើង ស្ត្រីពិការជួបបញ្ហារំលោភបំពាន បទដ្ឋានបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៩០% នៃអគារមិនទាន់ត្រូវបទដ្ឋានក្រសួងបានចេញនូវបទដ្ឋានជាតិជាច្រើន សង្ឃឹមការអនុវត្តបានល្អប្រសើរឡើងជាងនេះ។

### ១.២. សន្ទរកថាតំណាងនាយកដ្ឋានសុខមាលភាពជនពិការ

ចំណាប់អារម្មណ៍របស់លោក យៀប ម៉ាលីណូ ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះវិស័យពិការភាពនៅកម្ពុជា មានសន្ទុះគួរកត់សម្គាល់ ហើយវិស័យពិការភាពនៅកម្ពុជាមានភាពលេចធ្លោជាង បណ្តាប្រទេសជាច្រើននៅក្នុងតំបន់ ហើយមានប្រទេសខ្លះបាន និងកំពុងរៀនសូត្រពីកម្ពុជា ដូចជាឧបករណ៍វាយតម្លៃពិការភាព និងច្បាប់ការងារជនមានពិការភាពជាដើម។

### ១.៣. សន្ទរកថាបើកវេទិកាបើក របស់ឯកឧត្តម ឯកឧត្តម ញ៉ឹក វណ្ណារ៉ា (រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)

ជាកិច្ចចាប់ផ្តើម សន្ទរកថា និងការប្រកាសបើកកម្មវិធី របស់ឯកឧត្តម ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្ងៃនេះក្នុងនាមក្រសួងស.អ.យ. ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក-លោកស្រី ក្នុងសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ ស្តីពី “**បញ្ហាប្រឈមរវាងអ្នកទទួល និង អ្នកផ្តល់សេវាការងារដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា**” ។

បច្ចុប្បន្ន សុខុមាលភាពរបស់ជនមានពិការភាព ត្រូវបានយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋាន ជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ ជនពិការចូលបម្រើការងារ ក្នុងក្រសួងស្ថាប័នរដ្ឋ ចំនួន៤០ មានជនពិការចំនួន ២,៨៣៩ នាក់ ក្នុងនោះស្ត្រីពិការចំនួន ៧៣០នាក់ និងជនពិការកម្រិតធ្ងន់ ចំនួន១,៤៧៨នាក់ ស្មើនឹង៤,៤៧១នាក់ បើគិតជាភាគរយ ១,៩៣%។

ដើម្បីផ្តល់ឱកាសការងារដល់ជនពិការ ក្រសួង ស្ថាប័នរដ្ឋនីមួយៗ បាននិងកំពុងបន្តជ្រើសរើសឲ្យគ្រប់តាមអត្រាកំណត់ ២% ស្របតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។ ទន្ទឹមនឹងនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមាននាយកដ្ឋានសុខមាលភាពជនពិការជាសេនាធិការ បាននិងកំពុងបន្តជំរុញការអនុវត្តអនុក្រឹត្យស្តីពីការកំណត់ អត្រានិងបែបបទជ្រើសរើសជនពិការឲ្យចូលបម្រើការងារក្នុងវិស័យឯកជន ដែលកាតព្វកិច្ចបានកំណត់ចំនួន ១% ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមផ្តល់ជាអនុសាសន៍សំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

១. បន្តជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិនានា ដែលកម្ពុជាបានផ្តល់សច្ចាប័នរួច ឲ្យទទួលបានលទ្ធផលល្អប្រសើរ ។

២.បន្តជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការនិងលិខិតបទដ្ឋានគតិយុត្ត នានា ដើម្បីប្រែក្លាយពីឯកសារដែលមានលើក្រដាសឲ្យទៅជាសកម្មភាពជាក់ស្តែងដើម្បីជួយបងប្អូនជនពិការ

៣. បន្តជំរុញក្រសួង ស្ថាប័ន និងផ្នែកឯកជន ឲ្យទទួលជនពិការចូលបម្រើការងារតាមអត្រាកំណត់ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការជ្រើសរើសជនពិការ ចូលបម្រើការងារ ដែលមាន២%សម្រាប់ស្ថាប័នសាធារណៈ និង១%សម្រាប់ផ្នែកឯកជន

៤. អំពាវនាវអង្គការជាតិ និងអន្តរជាតិ ជម្រុញនិងលើកកម្ពស់មុខរបរ បណ្តុះបណ្តាលផ្សេងៗដើម្បីឲ្យគាត់មានមុខរបរខ្លួនឯងប្រសើរជាងបំរើការងារឲ្យគេ

៥. ជម្រុញSpot អប់រំខ្លីៗ កាត់បន្ថយការរើសអើង និងលើកទឹកចិត្តជនមានពិការភាព

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះដៃគូអភិវឌ្ឍដូចជអង្គការ អុកហ្វាម កម្ពុជា , អង្គការសាលារៀនទន្សាយ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ដែលបានជួយឧបត្ថម្ភគាំទ្រដល់វិស័យពិការភាពនៅកម្ពុជាមកទល់ពេលនេះ ។

## ២. បទបង្ហាញ ការអនុវត្តល្អ និងសមិទ្ធផលនានា ស្តីពី ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់សេវាការងារ ការស្រាវជ្រាវអំពីវិស័យការងារ និង ជួយគាំទ្រសេវាដល់យុវជនមានពិការភាពនៅកម្ពុជា

### ២.១. បទបង្ហាញរបស់ បទបង្ហាញរបស់លោកយៀប ម៉ាលីណូ ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ ស្តីពីបញ្ហាប្រឈមរបស់ជនមានពិការភាព សិទ្ធិស្មើគ្នារបស់ជនពិការ ច្បាប់ ស្តីពីកិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ និងទិន្នន័យជនពិការចូលបម្រើការងារក្នុងស្ថាប័នរដ្ឋ និងឯកជន។

- បទបង្ហាញរបស់របស់លោកយៀប ម៉ាលីណូ ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ ស្តីពីបញ្ហាប្រឈមរបស់ជនមានពិការភាព។ *ព័តមានលំអិតសូមមើលឧបសម្ព័ន្ធ ០៥។*

### ២.២. បទបង្ហាញរបស់ តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់ ស្តីពី "បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្តល់សេវាការងារ ដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា"

- បទបង្ហាញរបស់តំណាងក្រុមការងាររៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់ចំនួន ៦ ស្ថាប័ន ដែល បង្ហាញពីលទ្ធផលដែលដៃគូអភិវឌ្ឍបានសម្រេចបាននិងកំពុងអនុវត្តនៅប្រទេសកម្ពុជា ។ របស់ស្ថាប័នទាំង ៦នោះរួមមាន៖ អង្គការបុគ្គលសារវ័ន្ត Essential Personal Cambodia( EPC ) ,អង្គការសាលារៀនទន្សាយ Rabbit School Organization( RSO ),អង្គការ អេក អាយ Humanity & Inclusion( HI ),អង្គការមូលនិធិកុមារពិការ Komar Pikar Foundation ( KPF ),អង្គការ ឡៃហ្វ៍រឺវើល Light for the World( LfW ),អង្គការជនពិការ

កម្ពុជា Cambodia Disabled Person Organization(CDPO)។ *ព័តមានលំអិតសូមមើលឧបសម្ព័ន្ធ ០៦។*

## ៣. បញ្ចាំងវិដេអូនិងចែករំលែកបទពិសោធន៍អំពីភាពជោគជ័យរបស់យុវជនមានពិការភាព

- បញ្ចាំងវីដេអូអំពីភាពជោគជ័យរបស់យុវជនមានពិការភាពភ្នែកដែលបានរៀននៅគ្រូសារថ្មី កំពុងបំរើការនៅក្រសួងការបរទេសនៃព្រះរាជាណាចក្រកម្ពុជា
- បញ្ចាំងវីដេអូអំពីភាពជោគជ័យរបស់យុវជនមានពិការភាពសតិបញ្ញាដែលបានរៀននៅអង្គការសាលារៀនទន្សាយ ហើយកំពុងបំរើការងារនៅផ្ទះសំណាក់មេតមាំងឃី (Mad Monkey Hostel)
- ការចែករំលែកបទពិសោធន៍របស់កញ្ញា ឱ សារ៉ាត់ ដែលមានពិការភាពកាយសម្បទាពីអង្គការបុគ្គលសារវន្តក្នុងការរកការងារធ្វើ

## ៤. ពិភាក្សាក្រុមតូចស្តីពី("បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្តល់សេវាការងារដល់យុវជនមានពិការភាព)

លទ្ធផលពិភាក្សាតាមក្រុមនីមួយៗមាននៅក្នុងឧបសម្ព័ន្ធទី០១នៃរបាយការណ៍នេះ។

## ៥. វេទិកាពិភាក្សា (សំណួរ ចម្លើយ ក្រុមធំ) ដោយមានការចូលរួមពីវាគ្មិន

**សំណួរ**

- តើ Website BongThom អាចបន្ថែម Filter នៅក្នុង Website PWDs បានអត់?
- ខាងជនពិការភ្នែក មានសមត្ថភាពច្រៀង និងលេងភ្លេង តែគ្មានឱកាសធ្វើការក្នុងភោជនីយដ្ឋាន ត្រូវទៅសុំភោជនីយដ្ឋានបកស្រាយបទចម្រៀង ។ ឧទាហរណ៍ ជនពិការភ្នែកដាក់ពាក្យសាលាភូមិន្ទរដ្ឋបាល បុគ្គលិកទទួលពាក្យឃើញយើងពិការភ្នែកចឹង សម្តែងឥរិយាបទរើសអើងពិការភាព តែថ្នាក់ដឹកនាំព្រមទទួលពាក្យ។
- សូមជួយពន្យល់ពាក្យ ការរើសអើង ?
- តើជនពិការអាចស្វែងរកការងារតាមរយៈ NEA របៀបណា?
- តើNEA មានទំនាក់ទំនងជាមួយNGOs និងក្រុមហ៊ុនដែរឬទេ?
- តើជនពិការចូលធ្វើការក្នុងស្ថាប័នរដ្ឋ និងឯកជនបានប៉ុន្មានភាគរយ?

**ចំលើយ**

- មិនបានដឹងពីតួលេខ ព្រោះមិនបានកាន់ទិន្នន័យ
- សូមជនពិការកុំបាក់ទឹកចិត្ត ដោយសារជនមិនពិការក៏ពិបាករកការងារធ្វើដែរ ដោយសារអ្នកខ្លះធ្វើការខុសជំនាញ
- លើកទឹកចិត្តជនពិការរៀនជំនាញ ធ្វើការច្នៃប្រឌិត ទេពកោសល្យ ដោយសារអ្នកខ្លះមិនចាំបាច់បញ្ចេញរូបរាង អាចថាច្រៀងក្នុងហាង(អ្នកខ្លះស្តាប់ភ្លេងពេលញ៉ាំបាយ)

- Soft Skill មានសារៈសំខាន់ជាង Hard Skill
- ចំនុចសំខាន់សមត្ថភាព និងជំនាញជារឿងសំខាន់
- " រើសអើង" មិនយកចិត្តទុកដាក់ ព្រងើយកន្តើយ បរិស្ថានអត់ជម្រាល
- ធម្មតាក្រុមហ៊ុនប្រកាសជ្រើសរើសមុន ហើយបានរើសតាមក្រោយ អាចយូរ ប៉ុន្តែជនពិការត្រូវតែដាក់ពាក្យ
- NEA ជាស្ថាប័នរដ្ឋ ជាភ្នាក់ងារជួយរកការងារឲ្យធ្វើ និយោជិកអាចទៅរក NEA ហើយ NEA បើកទទួលជួយទាំងអស់មិនថាជនពិការ ឬជនមិនពិការទេ។ មានការបណ្តុះបណ្តាលជំនាញ មានវេទិកាសម្រាប់អ្នកស្វែងរកការងារធ្វើពេលជនពិការចុះឈ្មោះ NEA ដាក់ចូលទៅក្នុង System
- ជនពិការនៅមានកម្រិតក្នុងការរកការងាធ្វើតាមរយៈ NEA
- NEA បានសម្របសម្រួលដូចជា ជម្រាល បន្ទប់ទឹក ងាយស្រួលដល់ជនពិការ
- កន្លងមក NEA បានធ្វើការសហការជាមួយ NGOs ដូចជា អង្គការគ្រួសារថ្មី ក្នុងការផ្គូរផ្គងការងារ
- NEA មិនមែនជាម្ចាស់ជំនួយ គ្រាន់តែជាភ្នាក់ងារស្វែងរកការងារ តែមិនទាន់មានគ្រប់ខេត្ត-ក្រុងទេ

**សំណូមពរ**

1. កុំអោយរើសអើងទាំងមិនទាន់បានបញ្ចេញសមត្ថភាព
2. ក្រសួងស.អ.យ. និងមន្ទីរ គួរផ្តល់ឱកាសការងារ ដើម្បីលើកទឹកចិត្តដែលគាត់ជំនះតស៊ូតាំងពីតូច ពិសេសអ្នកដែលត្រូវគ្រួសាររារាំង
3. វិស័យឯកជនគួរតែផ្តល់ឱកាស និងលើកទឹកជនពិការ
4. កម្មវិធីអភិវឌ្ឍន៍មនុស្សសំណូមពរប្រើតែពាក្យ "ថ្លង់" ព្រោះដោយសារពួកគាត់ស្តាប់មិនលឺ ទើបនិយាយមិនបាន
5. សុំគ្រប់ស្ថាប័នពាក់ព័ន្ធ និងសារព័ត៌មានផ្សព្វផ្សាយប្រភេទពិការភាពតាំងពីតូចក្នុងប្រព័ន្ធអប់រំ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
6. ត្រូវការគ្រូជំនាញដើម្បីអប់រំកុមារពិការ(អប់រំពិសេស)
7. មន្ទីររាជធានីភ្នំពេញចង់បានលេខទំនាក់ទំនងរបស់ក្រុមហ៊ុន អង្គការផ្សេងៗ ដើម្បីងាយស្រួលបញ្ជូនទៅទទួលសេវា
8. បង្ហិតសេវាឲ្យគៀកជនពិការ ដើម្បីបង្កភាពងាយស្រួល សុវត្ថភាព ជាពិសេសជនពិការជាស្ត្រី

**ការរំពឹងទុករបស់វិស័យឯកជនៈ**

- សង្ឃឹមថាពួកគាត់(ជនពិការ)ទទួលបាន Soft Skill, ការលើកទឹកចិត្ត, ថ្លៃប្រឌិត, (ប្រើការគិត សម្តីសំដៅទន់ភ្លន់)
- ការរំពឹងទុករបស់រដ្ឋាភិបាល(ជាពិសេសក្រសួងសុខាភិបាល)
- មានការជម្រុញលើកទឹកចិត្តឲ្យជនពិការរៀនឲ្យចប់ ដើម្បីប្រលងចូលធ្វើការរដ្ឋ
- ឪពុកម្តាយសូមជម្រុញកូនរៀនបន្ត ហើយឲ្យគាត់រៀនតាមចំណូលចិត្តរបស់គាត់។

## ៦. សន្ទរកថាសង្ខេប និង សកម្មភាពបន្ទាប់ របស់តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់

លោក អ៊ូច និមល តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់បានធ្វើការសង្ខេបនូវបញ្ហាប្រឈម និងដំណោះស្រាយដែលបានស្រង់ពីកិច្ចពិភាក្សាក្រុមតូចអំពីការ**ផ្តល់សេវាការងារដល់យុវជនមានពិការភាព**

| បញ្ហាប្រឈម | ដំណោះស្រាយ អនុសាសន៍/ (១អាចលើសពីចំនួន) | ស្ថាប័នជាប់ពាក់ព័ន្ធស្ថាប័នទទួល/ (១អាចលើសពីចំនួន) ខុសត្រូវ |
|---|---|---|
| 1. ការរើសអើង និងខ្វះការយល់ដឹងពិការភាព ខ្វះទំនុកចិត្ត (និងជនពិការ អ្នកផ្តល់សេវា) | ▪ បង្កើនការផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពិការភាព និងនិតិវិធី | ▪ ក្រសួងសង្គមកិច្ច អង្គការ វិស័យឯកជន និង ជនមានពិការភាព |
| 2. កង្វះទទួលបានការអប់រំ ចំណេះដឹង សាលារៀន)និងសាលាវិជ្ជាជីវៈ( , | ▪ សហការជាមួយសាលារៀន និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ | ▪ ក្រសួងអប់រំ ក្រសួងងការងារ អង្គការ ជនមានពិការភាព |
| 3. ប្រឈមបញ្ហាស្វែងរកសេវាព្យាបាលសម្រាប់ជនពិការ | ▪ បង្កើនកិច្ចសហការលើសេវាស្តារ និងសុខភាពពីអ្នកពាក់ព័ន្ធ | ▪ ក្រសួងសង្គមកិច្ច និងក្រសួងសុខាភិបាល |
| 4. ខ្វះការទទួលបានព័តមានការងារពីពិការភាព និងការចែករំលែកព័តមានរវាងអ្នកពាក់ព័ន្ធ | ▪ បង្កើនការផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពិការភាព | ▪ ក្រសួងសង្គមកិច្ច ក្រសួងព័តមាន និងអង្គការ |
| 5. ចំណាយធនធានច្រើននៅពេលជ្រើសរើសជនពិការធ្វើការ | ▪ បង្កើនធនធានផ្នែកCSR នៅក្នុងស្ថាប័នឯកជន និង ផ្សារភ្ជាប់បណ្តាញផ្តល់ , ការលើកទឹកចិត្តពីក្រសួង បណ្ណទទួលស្គាល់ និង) (កាត់បន្ថយពន្ធ | ▪ ក្រសួងសង្គមកិច្ច ក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុន ( |
| 6. ការផ្សព្វផ្សាយពីការងារជនពិការនៅមានកម្រិត | ▪ បង្កើនការផ្សព្វផ្សាយពីច្បាប់គោលការណ៍ និងនិតិវិធីជ្រើសរើសជនមានពិការភាព | |

**ការងារត្រូវអនុវត្តបន្ត**

- ពង្រឹងនិងពង្រីកសមាជិកក្រុមការងារសម្រាប់ជនមានពិការភាព )National Employment for PwD forum)

- ~~កសាងផែនការ~~
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា ពិចារណាដើម្បីទទួលស្គាល់ក្រុមខាងលើជាក្រុមផ្លូវការថ្នាក់ជាតិ
- កសាងផែនការរយៈវែងសម្រាប់ក្រុមការងារសម្រាប់ជនមានពិការភាព )National Employment for PwD forum )
- ចង់ឃើញទទួលបានផ្តល់កិច្ចសហការពីក្រសួង ក្នុងការរៀបចំវេទិកានេះជារៀងរាល់ឆ្នាំ

RSO

## ៧. សុន្ទរកថាបិទកម្មវិធី (ដោយលោក យៀម ម៉ាលីណា) ប្រធាននាយកដ្ឋានអប់រំសុខមាលភាពជនពិការ)

ឥឥឥឥឥ

### ឧបសម្ព័ន្ធ៖

ឧបសម្ព័ន្ធទី០១៖ លទ្ធផលពិភាក្សាតាមក្រុមតូចលើបញ្ហាប្រឈម និង ដំណោះស្រាយក្នុងការទទួលការងាររបស់យុវជនមានពិការភាព

ឧបសម្ព័ន្ធទី០២៖ សន្ទរកថាបើករបស់ **ញឹក ឫទ្ធណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជនយុវនិតិសម្បទា

ឧបសម្ព័ន្ធទី០៣៖ សន្ទរកថារបស់លោកហ៊ុនទូច ប្រធានអង្គការសាលារៀនទន្សាយ

ឧបសម្ព័ន្ធទី០៤៖ សន្ទរកថារបស់ លោក យៀម ម៉ាលីណា ប្រធាននាយកដ្ឋានសុខមាលភាពជនពិការ

ឧបសម្ព័ន្ធទី០៥៖ បទបង្ហាញរបស់ លោក យៀម ម៉ាលីណា ប្រធាននាយកដ្ឋានសុខមាលភាពជនពិការ

ឧបសម្ព័ន្ធទី០៦៖ បទបង្ហាញរបស់ តំណាងក្រុមរៀបចំសិក្ខាសាលានិងវេទិកាពិគ្រោះយោបល់ ស្តីពី "បញ្ហាប្រឈមរវាងអ្នកទទួល និងអ្នកផ្តល់សេវាការងារ ដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា"

ឧបសម្ព័ន្ធទី០៧៖ បញ្ជីវត្តមានអ្នកចូលរួមវេទិការ

ឧបសម្ព័ន្ធទី០៨៖ របៀបវារៈសិក្ខាសាលានិងវេទិកាថ្នាក់ជាតិស្តីពី "បញ្ហាប្រឈមរវាងអ្នកទទួលសេវាអ្នកផ្តល់សេវាការងារដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា"

## ឧបសម្ព័ន្ធទី០១៖ លទ្ធផលពិភាក្សាតាមក្រុមតូចលើបញ្ហាប្រឈម និង ដំណោះស្រាយក្នុងការទទួលការងាររបស់យុវជនមានពិការភាព

### ក្រុមទី១៖ ក្រុមអាណាព្យាបាល (Parents)

**ប្រធានបទ៖**បញ្ហាប្រឈម និង ដំណោះស្រាយក្នុងការទទួលសេវាការងារដល់យុវជនមានពិការភាព

| បញ្ហាប្រឈម | ដំណោះស្រាយ/អនុសាសន៍ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|
| 1. ប្រឈមការរើសអើងក្នុងសង្គម<br>2. ប្រឈមស្វែងរកសាលារៀន<br>3. ប្រឈមក្នុងការទទួលសេវាព្យាបាល<br>4. ប្រឈមនឹងការស្វែងរកការងារធ្វើរបស់ជនមានពិការភាព<br>5. ឪពុកម្តាយខ្វះការយល់ដឹង<br>6. ប្រឈម និងការប្រើអំពើហឹង្សាពិសេសស្ត្រីពិការ( មានការចាប់រំលោភ ) | 1. បញ្ជ្រាបក្នុងការផ្សព្វផ្សាយអំពីសមត្ថភាពជនពិការក្នុងការសិក្សា<br>2. ស្នើសុំអោយមានសាលាបង្រៀនអប់រំពិសេស តាមថ្នាក់មូលដ្ឋានគ្រប់ខេត្ត-ក្រុង<br>3. ស្នើសុំអោយមានការចូលរួមពីក្រសួងសុខាភិបាល,សុំអោយមានប័ណ្ណសម្គាល់ពិការភាពក្នុងការព្យាបាល, បញ្ជ្រាបការយល់ដឹងពីពិការភាពដល់គ្រូពេទ្យ<br>4. សុំអោយវិស័យឯកជន និងរដ្ឋផ្តល់ឱកាសការងារដល់ជនមានពិការភាព,មើលពីសមត្ថភាពជាជាងពិការភាព<br>5. ស្នើសុំអោយមានការចូលរួមពីអាណាព្យាបាល<br>6. ស្នើសុំអាជ្ញាធរពាក់ព័ន្ធឲ្យយល់ច្បាស់អំពីអំពើហឹង្សា ,ពង្រឹងច្បាប់ និងទោសទណ្ឌដល់ជនល្មើស | 1. មាតាបិតា អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ<br>2. ក្រសួងអប់រំ<br>3. ក្រសួងសុខាភិបាល និងក្រសួងស.អ.យ.<br>4. ក្រុមហ៊ុនឯកជន រដ្ឋ<br>5. អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ<br>6. ក្រសួងកិច្ចការនារី អាជ្ញាធរមូលដ្ឋាន |

## **ក្រុមទី២៖ ក្រុមវិស័យឯកជនដែលផ្តល់ការងារ** ( Employer )

**ប្រធានបទ៖**បញ្ហាប្រឈមក្នុងការផ្តល់សេវាការងារដល់យុវជនមានពិការភាព

| បញ្ហាប្រឈម | ដំណោះស្រាយ/អនុសាសន៍ |
|---|---|
| 1. សមត្ថភាពចំណេះដឹងស្របទៅតាមទីផ្សារ<br>2. ជំនាញ និងចំណេះដឹងរបស់ក្រុមនិយោជក និងបុគ្គលិក<br>3. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត<br>4. ឧបករណ៍ និងសម្ភារៈជួយសម្រួលការងារ<br>5. បទបញ្ជា និងគោលនយោបាយ<br>6. ផលិតភាពការងារ (នៅមានកម្រិត)<br>7. ត្រូវការពេលវេលាច្រើនសម្រាប់រំលឹក/ជួយ<br>8. ចំណាយបន្ថែមទៅលើធនធានមនុស្ស/សម្ភារៈ<br>9. អោយតម្លៃខ្លួនឯងទាប Soft Skill<br>10. ពិការក្នុងការទំនាក់ទំនង<br>11. -ការយល់ដឹងរបស់ស្ថាប័ន | ▪ ពង្រឹងចំណេះដឹង និងជំនាញស្របតាមទីផ្សារ<br>▪ បង្រៀនពីចំណេះដឹងពីការធ្វើការងារជាមួយជនមានពិការភាព<br>▪ បញ្ជ្រាបការយល់ដឹងពាក់ព័ន្ធទៅនឹងសិទ្ធិ. ច្បាប់ស្ដីពីជនពិការ<br>▪ បង្កើត និងកែលម្អ និងជម្រុញការអនុវត្តទៅលើហេដ្ឋារចនាសម្ព័ន្ធនៅតាមស្ថាប័ន និងទីសាធារណៈ<br>▪ សម្របសម្រួលសម្ភារៈចាំបាច់របស់ជនមានពិការភាព<br>▪ បង្កើត និងផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយ និងបទបញ្ជា ដើម្បីជួយគាំទ្រដល់បុគ្គលិកជនមានពិការភាព<br>▪ ធ្វើការវាយតម្លៃ/បង្កើនលទ្ធភាព ផលិតកម្មការងារ<br>▪ រដ្ឋមានវិធានការលើកទឹកចិត្ត ឬប័ណ្ណសរសើរផ្សេងៗ<br>▪ ផ្តល់វគ្គបណ្តុះបណ្តាលជំនាញបន្ថែម Soft Skill<br>▪ ស្ថាប័នត្រូវមានកញ្ចប់ CSR (ទំនួលខុសត្រូវសង្គម) |

## ក្រុមទី៣៖ ក្រុមទីភ្នាក់ងារផ្តល់ការងារ ( Job Agency )

**ប្រធានបទ៖** បញ្ហាប្រឈម និងដំណោះស្រាយក្នុងការផ្តល់សេវាការងារដល់យុវជនមានពិការភាព

| បញ្ហាប្រឈម | ដំណោះស្រាយ/អនុសាសន៍ |
|---|---|
| 1. ការរើសអើងបែបវិជ្ជមាន ( Positive discrimination )<br>2. ពុំបានដឹងអំពីព័ត៌មានពីក្រសួងសង្គមកិច្ចអំពីការងារជួយជនពិការ<br>3. មានជនពិការមកទំនាក់ទំនងជាមួយ នៅមានកម្រិត | ▪ បង្កើនកិច្ចសហការជាមួយដៃគូពាក់ព័ន្ធ<br>▪ បង្កើនការផ្សព្វផ្សាយឱកាសការងារ<br>▪ គេហទំព័រ/Filler for PWDs |

## ក្រុមទី៤៖ ស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិ ( National Level )

**ប្រធានបទ៖**បញ្ហាប្រឈម និងដំណោះស្រាយក្នុងការផ្តល់សេវាការងារដល់យុវជនមានពិការភាព

| បញ្ហាប្រឈម | ដំណោះស្រាយ/អនុសាសន៍ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|
| 1. ការរើសអើង<br>2. សមត្ថភាពរបស់ជនពិការនៅមានកំរិត<br>3. ពុំមានជនពិការចូលមកដាក់ពាក្យ<br>4. ទំនាក់ទំនងជាមួយជនពិការភាពនៅមានកំរិត( គរ ថ្លង់ ខ្សោយសត្តិបញ្ញា ) | ▪ ផ្សព្វផ្សាយពីច្បាប់ និងសិទ្ធិទទួលបានការងាររបស់ជនពិការ<br>▪ បណ្តុះបណ្តាលជំនាញនិងពង្រឹងបន្ថែម<br>▪ ផ្តល់ការងារសមស្របតាមសមត្ថភាព<br>▪ ផ្សព្វផ្សាយលើកទឹកចិត្តជម្រុញ ផ្តល់អាទិភាពឲ្យពួកគាត់ចូលមកដាក់ពាក្យ<br>▪ ផ្តល់ភាពងាយស្រួលដល់ជនពិការចូលមកដាក់ពាក្យ<br>▪ បណ្តុះបណ្តាលភាសា & របៀបទំនាក់ទំនងជាមួយជនពិការដល់បុគ្គលិក | ▪ ស្ថាប័នរដ្ឋ និងឯកជន<br>▪ ស្ថាប័នពាក់ព័ន្ធ + NGO/ឯកជន<br>▪ NGO+ស្ថាប័នផ្ទាល់ |

## ក្រុមទី៥៖ ក្រុមអជ្ញាធរថ្នាក់ក្រោមជាតិ ( Sub-national level )

**ប្រធានបទ៖**បញ្ហាប្រឈម និងដំណោះស្រាយក្នុងការផ្តល់សេវាការងារដល់យុវជនមានពិការភាព

| បញ្ហាប្រឈម | ដំណោះស្រាយ/អនុសាសន៍ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|
| 1. ស្ថានភាពគ្រួសារខ្វះការគាំទ្រ<br>2. កេងចំណេញកំលាំងពលកម្ម<br>3. មានការរើសអើងពីសង្គម<br>4. ខ្វះទំនុកចិត្តលើយុវជនពិការ<br>5. ចំណេះដឹងជនមានពិការភាពនៅមានកំរិត<br>6. ផ្សព្វផ្សាយពីពិការភាពពុំទាន់បានទូលំទូលាយ (ខ្វះថវិកា)<br>7. ខ្វះភាពទំនាក់ទំនងជាមួយស្ថាប័ន នានា<br>8. មានឱកាសការងារតែគ្មានបរិយាកាសការងារ<br>9. ឱកាសបរិយាកាសនៃការចូលរួមក្នុងសង្គម | 1. ធ្វើការសម្របសម្រួល<br>2. ធ្វើការផ្សព្វផ្សាយពីច្បាប់គោលនយោបាយ, អនុសញ្ញា<br>3. ពិគ្រោះយោបល់<br>4. ហ្វឹកហាត់បច្ចេកទេសជំនាញវិជ្ជាជីវៈ<br>5. ស្វែងរកការគាំទ្រដើម្បីធ្វើការផ្សព្វផ្សាយ<br>6. បង្កើនការទំនាក់ទំនងល្អ<br>7. ស្វែងរកឱកាសជួប<br>8. សាងសង់ហេដ្ឋារចនាសម្ព័ន្ធ(បរិយាកាសការងារសម្រាប់ជនពិការ) | ▪ អាជ្ញាធរ, គ្រួសារ ស្ថាប័នពាក់ព័ន្ធ<br>▪ ស្ថាប័នពាក់ព័ន្ធ<br>▪ អាជ្ញាធរស្ថាប័នពាក់ព័ន្ធ<br>▪ អង្គការ ស្ថាប័នពាក់ព័ន្ធ<br>▪ អង្គការនានា, សប្បុរសជន<br>▪ ម្ចាស់អង្គភាព....រដ្ឋាភិបាល |

## ក្រុមទី៦៖ ក្រុមអង្គការមិនមែនរដ្ឋាភិបាល( NGOs )

**ប្រធានបទ៖**បញ្ហាប្រឈម និង ដំណោះស្រាយក្នុងការទទួលសេវាការងារដល់យុវជនមានពិការភាព

| បញ្ហាប្រឈម | ដំណោះស្រាយ/អនុសាសន៍ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|
| 1. ខ្វះការយល់ដឹងពីពិការភាពរបស់អ្នកផ្តល់សេវា/និយោជក...<br>2. តាមស្ថាប័ន/និយោជកមិនផ្តល់ឱកាសដល់ជនពិការពេលទទួលការងារ.<br>3. ខ្វះការទទួលព័ត៌មានពីគ្រប់ស្ថាប័ន/យុវជនពិការ | 1. ផ្តល់ការគាំទ្រ, ការតាមដាន,...<br>2. បណ្តុះបណ្តាល, ការផ្សព្វផ្សាយ<br>3. គៀងគលអ្នកសម្រេចចិត្តខ្ពស់ឲ្យចូលរួម, ជនពិការខ្លួនឯង<br>4. ការកសាងផែនការ&បទដ្ឋានក្នុងការអនុវត្តន៍រួមគ្នា.<br>5. ជម្រុញការអនុវត្តន៍ច្បាប់ឲ្យមានប្រសិទ្ធភាព<br>6. តាមស្ថាប័ន/និយោជកអនុវត្តន៍តាមច្បាប់ដែលមានស្រាប់<br>7. កសាងសមត្ថភាពជនពិការស្របតាមជំនាញការងារ...<br>8. ផ្សព្វផ្សាយព័ត៌មានការងារឲ្យបានទូលាយ&ត្រូវគោលដៅ<br>9. ពង្រឹងសមត្ថភាពជនពិការក្នុងការស្រាវជ្រាវព័ត៌មាន<br>10. បណ្តាញ/ភាពជាដៃគូរ | ▪ ក្រសួងសង្គកិច្ច(រដ្ឋបាលសិទ្ធិជនពិការ) ក្រសួងការងារ, ក្រសួងព័ត៌មាន អង្គភាពដៃគូ<br>▪ ស.អ.យ(រដ្ឋបាលសិទ្ធជនពិការ), ក្រសួងការងារ<br>▪ ជនពិការ, អង្គការពាក់ព័ន្ធ, ក្រុមហ៊ុន<br>▪ TVET, ក្រសួងព័ត៌មាន, ទូរទស្សន៍... |

## ឧបសម្ព័ន្ធទី០២៖ សន្ទរកថាបើករបស់ ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន យុវនីតិសម្បទា

***សូមគោរព !***

- *ឯកឧត្តម ហាច ហ៊ិន អនុរដ្ឋលេខាធិការ ក្រសួងស.អ.យ.*
- *ឯកឧត្តម ចាប បុទ្ធី អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*
- *ឯកឧត្តម គង់ សុភណាក៏ ទីប្រឹក្សា ក្រសួងស.អ.យ.*
- *ឯកឧត្តម ពុំ បូរ៉ាត់ ទីប្រឹក្សា ក្រសួងស.អ.យ.*
- *លោក អៀម សារ៉ាត់ តំណាងអគ្គលេខាធិការក្រុមប្រឹក្សាសកម្មភាពជនពិការ*
- *លោក យៀប ម៉ាលីណូ ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ*
- *លោកស្រី សុខ ចន្ទធី ប្រធានកម្មវិធីនៃអង្គការ* Oxfarm Cambodia
- *លោក ហ៊ីន ទូច នាយកប្រតិបត្តិ អង្គការសាលារៀនទន្សាយ*
- *ឯកឧត្តម លោកជំទាវ លោក-លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ជាទីគោរពរាប់អាន !*

ថ្ងៃនេះ ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមជាមួយ **ឯកឧត្តម លោកជំទាវ លោក-លោកស្រី** ក្នុងសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ ស្តីពី **"បញ្ហាប្រឈមរវាងអ្នកទទួល និង អ្នកផ្តល់សេវាការងារដល់យុវជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា"** ។

ក្នុងឱកាសនេះផងដែរ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះក្រុមការងារនាយកដ្ឋានសុខុមាលភាពជនពិការ ដែលមានការចូលរួមសហការរៀបចំពីអង្គការ Rabbit School ដែលបានរៀបចំសិក្ខាសាលា និងវេទិកា

នេះឡើងជាលើកដំបូង ក្នុងគោលបំណងដើម្បីពិភាក្សាអំពីឧបសគ្គ និងបញ្ហាប្រឈមដែលរារាំងអំពីការដាក់បញ្ចូលយុវជនមានពិការភាព និងស្វែងរកដំណោះស្រាយសមស្របនឹងឧបសគ្គទាំងនេះ ។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកវិស័យពិការភាពជាវិស័យអាទិភាពនៅក្នុងវិស័យអាទិភាពធំៗដទៃទៀត ដោយបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ការពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការជំរុញកិច្ចការពារ លើកកម្ពស់សិទ្ធិ និងសុខុមាលភាពជនពិការ ស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ។

បច្ចុប្បន្ន សុខុមាលភាពរបស់ជនមានពិការភាព ត្រូវបានយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋាន ជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ ជនពិការចូលបម្រើការងារ ក្នុងក្រសួងស្ថាប័នរដ្ឋ ចំនួន៤០ មានជនពិការចំនួន **២,៨៣៩**នាក់ ក្នុងនោះ**ស្ត្រីពិការចំនួន ៧៣០**នាក់ និងជនពិការកម្រិតធ្ងន់ ចំនួន១,**៤៧៨** នាក់ ស្មើនឹង៤,**៤៧**១នាក់ បើគិតជាភាគរយ ១,**៩៣**%។

បច្ចុប្បន្នដើម្បីផ្តល់ឱកាសការងារដល់ជនពិការ ក្រសួង ស្ថាប័នរដ្ឋនីមួយៗ បាននិងកំពុងបន្តជ្រើសរើសឲ្យគ្រប់តាមអត្រាកំណត់ ២% ស្របតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។ ទន្ទឹមនឹងនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមាននាយកដ្ឋានសុខុមាលភាពជនពិការជាសេនាធិការ បាននិងកំពុងបន្តជំរុញការអនុវត្តអនុក្រឹត្យស្តីពីការកំណត់ អត្រានិងបែបបទជ្រើសរើសជនពិការឲ្យចូលបម្រើការងារក្នុងវិស័យឯកជន ដែលកាតព្វកិច្ចបានកំណត់ចំនួន ១% ។

កន្លងមកក៏ដូចបច្ចុប្បន្ន **រាជរដ្ឋាភិបាលកម្ពុជា** តែងបានអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់លើបងប្អូនជនពិការឲ្យមានជំនាញ មុខរបរ និងការងារ សមរម្យ ដើម្បីកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើនការយកចិត្តទុកដាក់គិតគូរអំពីផលប្រយោជន៍ និងការលើកតម្កើងជីវភាពរស់នៅ របស់ជនពិការឲ្យបានសមរម្យ ស្របតាមសេដ្ឋកិច្ចជាតិ ព្រមទាំងបានបំផុសលើកទឹកចិត្តដល់ពលរដ្ឋ សប្បុរសជន ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលនានា ឲ្យចូលរួមឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តដល់ជនពិការផងដែរ ។

ក្នុងឱកាសនេះផងដែរ ខ្ញុំសូមអរគុណទៅដល់ អង្គការដៃគូពាក់ព័ន្ធមួយចំនួនដែលបានចូលរួមសហការឧបត្ថម្ភទាំងថវិកា ធនធាន និងបច្ចេកទេស មានដូចជា ៖

- អង្គការមូលនិធិកុមារកម្ពុជា ( Cambodia Children's Fund)
- អង្គការឡាយហ្វ័រឌឺវើល( Ligth For The World)
- អង្គការអេច អាយ(Human and Inclusion)
- អង្គការជនពិការកម្ពុជា (CDPO)

ដែលបានចូលរួមសហការគាំទ្ររៀបចំសិក្ខាសាលា និងវេទិកា នេះឡើង ដើម្បីជំនួបពិភាក្សារកដំណោះស្រាយពីបញ្ហាប្រឈមនៃការស្វែងរកការងារធ្វើរបស់ជនមានពិការភាពក៏ដូចជាបញ្ហាប្រឈមរបស់អ្នកផ្តល់សេវាការងារ

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមផ្តល់ជាអនុសាសន៍សំខាន់ៗមួយចំនួនដូចខាងក្រោម ៖

១. បន្តជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិនានា ដែលកម្ពុជាបានផ្តល់សច្ចាប័នរួច ឲ្យទទួលបានលទ្ធផលល្អប្រសើរ ។

